នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
ចូល លេខ: 2198 របក១
ម៉ោង: 2: 50 ថ្ងៃទី 14 /08 /2018
បញ្ជូនទៅ:......................................
អ្នកទទួល:......................................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៨/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-យោងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

ប្រការ១._

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១.ឯកឧត្តម | **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២.លោកជំទាវ | **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣.ឯកឧត្តម | **ជូ ទីជិត្ត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤.ឯកឧត្តម | **ម៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៥.ឯកឧត្តម | **ឃឹម ប៊ុនសុខ** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | អនុប្រធាន |
| ៦.ឯកឧត្តម | **ស៊ុ តិរិទ្ធ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧.ឯកឧត្តម | **ទី ច័ន្ទ្រផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨.ឯកឧត្តម | **ជា ប៊ូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៩.ឯកឧត្តម | **និត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១០.ឯកឧត្តម | **ថៃ នរៈសត្យា** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១១.ឯកឧត្តម | **ស៊ីម យ៉ារីន** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១២.ឯកឧត្តម | **ឈន សុភាព** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣.ឯកឧត្តម | **សុខ គុខហាប់** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៤.ឯកឧត្តម | **អ៊ុន ធីម** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១៥.ឯកឧត្តម | **លី សិរិទ្ធិ** | អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ១៦.ឯកឧត្តម | **សុខ សង្វារ** | អគ្គនាយករងអាជ្ញាធរជាតិអប្សរា | សមាជិក |

ប្រការ២._

គណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប មានតួនាទី និងភារកិច្ចដូចតទៅ÷

-រៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងខេត្តសៀមរាបដោយផ្អែកលើប្លង់មេនៃការប្រើប្រាស់ដីធ្លីរបស់ខេត្តសៀមរាប ដើម្បីធានាបាននូវការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយចីរភាព មានរបៀបរៀបរយ មានសណ្តាប់ធ្នាប់ល្អ ទាំងការអភិរក្ស និងការអភិវឌ្ឍទីក្រុងសៀមរាប

-សិក្សា រៀបចំបង្កើតឱ្យមានផលិតផលទេសចរណ៍ថ្មីៗនៅក្នុងខេត្តសៀមរាប សំដៅបង្កើនការទាក់ទាញភ្ញៀវទេសចរបន្ថែម និងពន្យារការស្នាក់នៅរបស់ភ្ញៀវ

-ពិនិត្យ សិក្សា រៀបចំឱ្យមានជាព្រឹត្តិការណ៍វប្បធម៌ សិល្បៈកំសាន្តធំៗនៅពេលយប់ ទាំងបុរាណ និងទំនើប ទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ ដែលអាចសហការរៀបចំជាមួយវិស័យឯកជន នៅតាមទីតាំងប្រាសាទមួយចំនួន ដោយយើងអាចគ្រប់គ្រងរក្សាការពារ អភិរក្សបាន និងមិនធ្វើឱ្យប៉ះពាល់ដល់ទីតាំងប្រាសាទ

-ពិនិត្យ សិក្សា រៀបចំរមណីយដ្ឋានទេសចរណ៍ធម្មជាតិ និងរមណីយដ្ឋានប្រវត្តិសាស្ត្រ ដែលមាន មានសក្តានុពលផ្សេងទៀតនៅក្នុងខេត្តសៀមរាប

-ធ្វើរបាយការណ៍អំពីលទ្ធផល ឬរបាយការណ៍អំពីវឌ្ឍនភាពការងាររបស់ខ្លួនជូនរាជរដ្ឋាភិបាលជ្រាប និងសុំការណែនាំ យ៉ាងយូរបីខែម្តង

-បំពេញភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ប្រការ៣._

សមាជិកគណៈកម្មការអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានគណៈកម្មការ អាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការងារ និងកិច្ចប្រជុំជំនួស។

ប្រការ៤._

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិបង្កើតលេខាធិការដ្ឋាន និងក្រុមការងារបច្ចេកទេសតាមការចាំបាច់ ដែលមានសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ។

ប្រការ៥._

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងទេសចរណ៍សម្រាប់ដំណើរការការងាររបស់ខ្លួន។

ប្រការ៦._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ៧._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែសីហា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ